ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

តុលាការព្រហ្មទណ្ឌ

**សំណុំរឿងព្រហ្មទណ្ឌលេខ ២១៤២ អ.ក**

ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១

**សំណុំរឿងស៊ើបសួរលេខ ១១៥២ ស.ស**

ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១

**សំណុំរឿងជំនុំជម្រះលេខ ៣២១ ជ.រ**

ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២

**សាលក្រមព្រហ្មទណ្ឌលេខ ៧៣ ឋ**

ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកណ្តាល

កាលបរិច្ឆេទនៃសវនាការ ៖ ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២។

សាលសវនាការ និងពេលវេលា ៖ សាល ០១ ម៉ោង ១០ ព្រឹក។

កាលបរិច្ឆេទនៃការប្រកាសសាលក្រម ៖ ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២។

សាលសវនាការ និងពេលវេលា ៖ សាល ០១ ម៉ោង ១១ ព្រឹក។

ក្រោមសមាសភាពជំនុំជម្រះ រួមមាន៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល និងជាចៅក្រមជំនុំជម្រះ

**តំណាងអយ្យការ**

លោកស្រី [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្តាល

**ក. អំពីអត្តសញ្ញាណជនជាប់ចោទ**

**១.** ឈ្មោះ [redacted] **សេងលី** ភេទប្រុស កើតថ្ងៃទី០១ ខែឧសភា ឆ្នាំ១៩៩៨ (អាយុ ២៣ ឆ្នាំ) សញ្ជាតិខ្មែរ។

ទីកន្លែងកំណើតនៅភូ[redacted] ខេត្តកណ្តាល។

ទីលំនៅភូមិ[redacted] ខេត្តកណ្តាល។

ឪពុកឈ្មោះ [redacted]**វី** (រ) ម្តាយឈ្មោះ [redacted] **ស៊ិន** (ស) នៅលីវ។

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ៖ គ្មាន។

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ**ឈ្មោះ [redacted] សេងលី៖

លោកស្រី[redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

លោក[redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

លោក[redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យ៖ **ក្រុមហ៊ុនមេធាវី ដ័ន & ដ័ន ភ្នំពេញ** (Duan & Duan Phnom Penh Law Firm) អាសយដ្ឋាននៅអគារបារាំង (ក្បែរតុលាការកំពូល) ផ្លូវសុធារស សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

**២.** ឈ្មោះ [redacted] **សួយគ្រាយ** ភេទប្រុស កើតឆ្នាំ១៩៩៨ (អាយុ ២៣ ឆ្នាំ) ជនជាតិខ្មែរ សញ្ជាតិខ្មែរ។



Scanned with CamScanner

ទីកន្លែងកំណើតនៅភូ[redacted] ខេត្តកណ្ដាល។

ទីលំនៅភូ[redacted] ខេត្តកណ្ដាល។

ឪពុកឈ្មោះ [redacted]មនោ (រ) ម្ដាយឈ្មោះ [redacted] ឡូន (រ) នៅលីវ។

ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ៖ គ្មាន។ (គេចខ្លួន)

ត្រូវជាប់ចោទពីបទ **អំពើលួច** ប្រព្រឹត្តនៅភូមិព្រែកក្របៅទី១ ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីអំឡុងខែធ្នូ និងថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

៣. ឈ្មោះ [redacted] **រិត** ភេទប្រុស កើតថ្ងៃឆ្នាំ ១៩៩៤ (អាយុ ២៧ ឆ្នាំ) ជនជាតិខ្មែរ សញ្ជាតិខ្មែរ។

ទីលំនៅភូ[redacted] ខេត្តកណ្ដាល។

ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ៖ មិនត្រូវបានដឹង។ (គេចខ្លួន)

ត្រូវជាប់ចោទពីបទ **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅភូមិពុកឬស្សីក្រោម ឃុំពុកឬស្សី ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

**គ. អំពីអត្តសញ្ញាណជនរងគ្រោះ**

ឈ្មោះ [redacted] **ច័ន្ទម៉ូណាក់** ភេទប្រុស អាយុ ៣៧ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ។

ទីលំនៅភូមិឃ្លាំងមឿនត្បូង ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល។

**សំណុំរឿងព្រហ្មទណ្ឌនេះបញ្ជូនមកជំនុំជម្រះតាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ២៨៣ ដក.ដស ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល ដែលមាន៖**

**អង្គហេតុដែលប្ដឹងមកតុលាការ**

ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង ២០ និង ៣០ នាទី នៅចំណុចភូមិព្រែកក្របៅទី១ ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ឈ្មោះ [redacted] **សេងលី** និងឈ្មោះ [redacted] **ស្វាយត្រាយ** បានជិះម៉ូតូធ្វើសកម្មភាពលួចយកដែកអន្ទាសម្រាប់ធ្វើសំណង់របស់ឈ្មោះ [redacted] **ច័ន្ទម៉ូណាក់** ដែលទុកនៅក្រៅរបងផ្ទះចំនួន ០៣ ផ្ទាំង ពេលលួចបានហើយយកទៅលក់ឱ្យឈ្មោះ [redacted] **រិត** ជាអ្នកទិញអេតចាយ រស់នៅភូមិឬស្សីក្រោម។ បន្ទាប់មកជនរងគ្រោះបានដាក់ពាក្យបណ្ដឹង សមត្ថកិច្ចក៏ធ្វើការស្រាវជ្រាវធ្វើការឃាត់ខ្លួនឈ្មោះ [redacted] **សេងលី** តែម្ដង។ កន្លងមកឈ្មោះទាំងពីរនាក់ តែងតែធ្វើសកម្មភាពលួចទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋជាច្រើនលើកមកហើយ ហើយយកទៅលក់ឱ្យអ្នកទិញឈ្មោះ [redacted] **រិត** ជាញឹកញាប់។

**អំពីកិច្ចពិភាក្សាដេញដោលលើអង្គសេចក្ដី**

**ក. អំពីកិច្ចពិភាក្សាដេញដោលមុនពេលអង្គសេចក្ដី**

អំពីវិវាទកម្មស្ដីពីនិយតភាពនៃការរកោះហៅ តាមមាត្រា ៣២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖ ពុំមាន។

អំពីអញ្ញត្រកម្ម តាមមាត្រា ៣៤២ ដល់មាត្រា ៣៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖ ពុំមាន។

**ខ. អំពីកិច្ចពិភាក្សាដេញដោលលើអង្គសេចក្ដី**



Scanned with CamScanner

១. ការសួរចម្លើយជនជាប់ចោទ

១.១. ចម្លើយជនជាប់ចោទឈ្មោះ [redacted] សេងលី ចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌៖ កន្លងមកខ្ញុំធ្លាប់ប្រព្រឹត្តអំពើលួចទ្រព្យសម្បត្តិអ្នកដទៃ ជាមួយឈ្មោះ [redacted] ត្រាយ ភេទប្រុស អាយុ ២៣ ឆ្នាំ នៅភូមិជាមួយខ្ញុំយកទៅលក់ដើម្បីស៊ីចាយ និងទិញគ្រឿងញៀនជក់ ពេលខ្លះខ្ញុំដើរលួចទ្រព្យសម្បត្តិគេជាមួយឈ្មោះ លី ភេទប្រុស អាយុ ២៤ ឆ្នាំ នៅភូមិឃ្លាំងមឿងត្បូង និងឈ្មោះ ឌី ភេទប្រុស អាយុ ២៨ ឆ្នាំ នៅភូមិឃ្លាំងមឿងជើងជាមួយខ្ញុំដែរ។ នៅថ្ងៃទីមិនចាំ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង ១ រសៀល ឈ្មោះ ឌី បានលួចសត្វមាន់ពីភូមិព្រែកក្របៅ យកមកឱ្យខ្ញុំយកទៅលក់បន្តបានប្រាក់ ៣១,000 (បីម៉ឺនមួយពាក់) រៀល យកប្រាក់ទៅទិញថ្នាំញៀនជក់។ នៅថ្ងៃទីមិនចាំ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង ២ រសៀល ខ្ញុំបាទ និងឈ្មោះ [redacted] ត្រាយ បានដើររកលួចទ្រព្យសម្បត្តិគេ នៅភូមិពុកឬស្សីក្រោម ឃុំពុកឬស្សី ពេលដើរដល់ផ្ទះគេខ្ញុំមិនស្គាល់ឈ្មោះ ខ្ញុំបាទបានឃើញដែកដែលគេទុកចោល នៅក្បែររបងផ្ទះ ឃើញដូចនោះពួកខ្ញុំបានលួចដែកនេះ យកទៅលក់អេតចាយបានប្រាក់ ២៧,000 (ពីរម៉ឺនប្រាំពីរពាន់) រៀល ក្រោយមកខ្ញុំបាទ និងឈ្មោះ [redacted] ត្រាយ ដើរលួចទ្រព្យសម្បត្តិគេជាច្រើនលើកទៀត។ ដល់ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង ៨ និង ០០ នាទី យប់ ខ្ញុំបាទ និងឈ្មោះ [redacted] ត្រាយ បានជិះម៉ូតូឌុបគ្នាទៅលួចដែកចន្ទា នៅផ្ទះគេខ្ញុំមិនស្គាល់ឈ្មោះ នៅភូមិព្រែកក្របៅទី១ ឃុំព្រែកអំពិល ដែលផ្ទះនេះគេកំពុងធ្វើរបងពួកខ្ញុំលួចដែកចន្ទាមួយផ្កាំងដែលនៅខាងត្បូងផ្ទះ រួចពួកខ្ញុំបានជិះម៉ូតូឌុបគ្នាដោយឈ្មោះ [redacted] ត្រាយ ជាអ្នកឌុប ខ្ញុំបាទកាន់ដែកចន្ទាជិះខាងក្រោយ យកទៅលក់តូបគេទិញអេតចាយ នៅភូមិពុកឬស្សីក្រោម ឃុំពុកឬស្សី ពេលទៅដល់ខ្ញុំបាទមិនឃើញអ្នកទិញអេតចាយទេ ដោយតូបអេតចាយចាក់សោរ ខ្ញុំបាទបានដាក់ដែកចន្ទាមួយផ្កាំងផ្អែកនៅមុខតូបអេតចាយនេះ លុះដល់ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង ៦ ព្រឹក ខ្ញុំបាទqនិងឈ្មោះ [redacted] ត្រាយ ជិះម៉ូតូម៉ាកកុបជ្រុង70c ដោយឈ្មោះ [redacted] ត្រាយ ជាអ្នកឌុបទៅលក់ដែកចន្ទានេះ បានប្រាក់ ១០.៥០០ (មួយម៉ឺនប្រាំរយ) រៀល បានប្រាក់ហើយ ពួកខ្ញុំយកទៅទិញអីហូប។ លុះដល់ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង ១១ ព្រឹក សមត្ថកិច្ចនគរបាលបានឃាត់ខ្លួនខ្ញុំបាទបញ្ជូនមកអធិការដ្ឋាននគរបាលស្រុកខ្សាច់កណ្ដាល ចំណែកឈ្មោះ [redacted] ត្រាយ ខ្ញុំបាទមិនដឹងនៅទីណាទេ។

១.២. ចម្លើយជនជាប់ចោទឈ្មោះ [redacted] សេងលី ចំពោះមុខចៅក្រមស៊ើបសួរ៖ ខ្ញុំទទួលស្គាល់ចម្លើយនៅចំពោះមុខតំណាងអយ្យការទុកជាបានការដដែល។ សមតកិច្ចឃាត់ខ្លួនខ្ញុំនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ ដកហូតបានដែកទទារចំនួន ០១។ នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១ ខ្ញុំ និងឈ្មោះ [redacted] ស៊ុយត្រា បានជិះម៉ូតូទៅលួចទទាររបស់គេនៅចំណុចភូមិព្រែកក្របៅទី១ ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្ដាល ឈ្មោះ [redacted] ត្រាយ អ្នកឌុបទៅដល់ខ្ញុំជាអ្នកចុះយកទទារនោះ រួចជិះចេញមកលក់ឱ្យអ្នកទិញមិនស្គាល់ឈ្មោះ នៅពុកឬស្សី បានប្រាក់ចំនួន ១៥.000 រៀល ហើយប្រាក់នេះបានយកមកទិញនុំពងអន្សងហូបជាមួយឈ្មោះ [redacted] ត្រាយ អស់ហើយ។ ខ្ញុំធ្លាប់លួចចំនួន ០៣ លើក ហើយជាមួយឈ្មោះ [redacted] ត្រាយ លើកទី១ លួចមាន់នៅព្រែកក្របៅ លើកទី២ លួចដែកកំណាត់នៅពុកឬស្សី និងលើកទី៣ គឺលួចទទារនេះ រាល់បទល្មើសលួចទាំងពីរលើកពុំធ្លាប់បានសមត្ថកិច្ចចាប់ខ្លួនបានទេ ហើយក៏ដែលត្រូវបានតុលាការផ្ដន្ទាទោសម្ដងណាដែរ។ ចំពោះឈ្មោះ [redacted] រិត គឺជាអ្នកទិញទទារពីខ្ញុំដោយខ្ញុំស្គាល់ក្រោយពីសមត្ថកិច្ចឃាត់ខ្លួនបាន។



Scanned with CamScanner

១.៣. ចម្លើយជនជាប់ចោទឈ្មោះ [redacted] **សេងលី** នៅក្នុងកិច្ចពិភាក្សាដេញដោល៖ ខ្ញុំជាប់ចោទពីបទ លួចដែកគេ នៅភូមិព្រែកក្របៅ១ ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល។ ដំបូងខ្ញុំ និងមិត្តភក្តិឈ្មោះ [redacted] សួយត្រាយ បានជិះម៉ូតូចេញពីផ្ទះខ្ញុំ ទៅផ្ទះមិត្តភក្តិម្នាក់ទៀត ដោយឈ្មោះ [redacted] សួយត្រាយ ឌុបខ្ញុំ។ មិនទាន់ដល់ផ្ទះមិត្តភក្តិផង ពួកខ្ញុំឃើញដែកគេទុកនៅក្រៅរបង ឈ្មោះ [redacted] សុយត្រាយ ឱ្យខ្ញុំចុះទៅយកដែកបីផ្ទាំង លក់ឱ្យអេតចាយ។ ឈ្មោះ [redacted] សួយត្រាយ យក ២ ផ្ទាំង ខ្ញុំយក ១ ផ្ទាំង។ ពេលទៅដល់ផ្ទះអេតចាយ ផ្ទះនោះបិទទ្វារ ពួកខ្ញុំមកផ្ទះវិញ។ សមត្ថកិច្ចចាប់ខ្ញុំបាន ពេលខ្ញុំនៅផ្ទះ។ ខ្ញុំដឹងថា ផ្ទះនោះមានម្ចាស់ តែដោយសារឃើញទុកចោលនៅក្រៅរបង ខ្ញុំក៏យកទៅ។ ខ្ញុំធ្លាប់ប្រើប្រាស់គ្រឿងញៀន តែទើបតែប្រើប្រាស់ថ្មីៗនេះទេ។ ខ្ញុំធ្លាប់លួចចំនួន ៣ ដង លើកទី១ ខ្ញុំយកមាន់ទៅលក់ និងទិញគ្រឿងញៀន លើកទី២ ខ្ញុំយកដែកទៅលក់ និងទិញនំហូប។ ខ្ញុំធ្លាប់ជាប់ពន្ធាគារ ចំនួន ០៤ ខែមកហើយ ជាប់ពន្ធនាគារពិបាកណាស់ ខ្ញុំសន្យាថា ចេញទៅវិញ កែខ្លួនហើយ។

## ២. ការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី

**២.១.** ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ច័ន្ទម៉ូណាក់** ចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌៖ រយៈពេល ១០ ឆ្នាំមកហើយ ដែលខ្ញុំបាទ និងឈ្មោះ [redacted] **ភារម្យ** ភេទប្រុស នៅភូមិត្បូង ឃុំកោះចូរ៉ាម ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ធ្វើជាកម្មករសំណង់ និងរយៈពេលប្រហែល ៥ ខែ មកហើយ ដែលខ្ញុំ និងឈ្មោះ **ចាន់ ភារម្យ** ភេទប្រុស ដើរម៉ៅការធ្វើរបងផ្ទះ បន្ទប់ទឹក និងចាក់សាប។ នៅថ្ងៃទីមិនចាំ ខែកញ្ញា ឆ្នាំ២០២១ ខ្ញុំបាទជាមួយឈ្មោះ [redacted] **ភារម្យ** បានទទួលធ្វើរបងក្នុងដីឡូត៍របស់ឈ្មោះ **សឿន** ភេទប្រុស នៅភូមិព្រែកក្របៅទី ១ ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ចំពោះសម្ភារៈដូចជា ក្ដារពុម្ព និងរន្ទាសម្រាប់ធ្វើសំណង់ខ្ញុំបាទទុកនៅក្រៅរបងខ្លះ និងសម្ភារៈខ្លះទៀត ទុកនៅខាងក្នុងដីឡូត៍នេះមិនដែលយកមកទុកនៅផ្ទះទេ។ នៅថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោងប្រហែល ៧ ព្រឹក ខ្ញុំបាទជាមួយឈ្មោះ [redacted] **ភារម្យ** បាននាំគ្នាទៅធ្វើរបងដីរបស់ឈ្មោះ **សឿន** នោះបន្តទៀត រហូតដល់ម៉ោង ១១ ថ្ងៃ ខ្ញុំបាទជាមួយឈ្មោះ [redacted] **ភារម្យ** បានយកសម្ភារៈធ្វើសំណង់កន្ត្រៃ ស៊ីម៉ង់ ដែក ចប ទុកក្នុងរបងហើយចាក់សោរ ចំណែកក្ដារពុម្ព និងរន្ទា ខ្ញុំបាទទុកនៅក្រៅរបង ហើយខ្ញុំបាទ និងឈ្មោះ [redacted] **ភារម្យ** ក៏ជិះម៉ូតូមកផ្ទះសម្រាកចំនួន ០៥ ថ្ងៃ លុះដល់ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោងប្រហែល ៣ រសៀល ឈ្មោះ [redacted] **សុក្រិត** ជាមេប៉ុស្តិ៍ព្រែកអំពិលបានទូរស័ព្ទមក ប្រាប់ខ្ញុំថា ចោរលួចដែករន្ទាបងឯងធ្វើសំណង់អស់ហើយ ឥឡូវបងទៅមើលដែករន្ទារបស់បងឯងនៅអធិការដ្ឋាននគរបាលស្រុកខ្សាច់កណ្ដាល ព្រោះខ្ញុំបញ្ជូនមកស្រុកហើយ ពេលនិយាយទូរស័ព្ទរួច ខ្ញុំបាទ និងឈ្មោះ [redacted] ភារម្យ ក៏ជិះម៉ូតូមកអធិការដ្ឋាននគរបាលស្រុកខ្សាច់កណ្ដាល ពេលមកដល់ខ្ញុំបាទក៏ឃើញដែករន្ទារបស់ខ្ញុំចំនួន ៣ រន្ទា ហើយខ្ញុំបាទក៏ដាក់ពាក្យបណ្ដឹងនៅអធិដ្ឋាននគរបាលស្រុកខ្សាច់កណ្ដាល។

## ៥. ការស្ដាប់ចម្លើយសាក្សី

**៥.១.** ចម្លើយសាក្សីឈ្មោះ [redacted] **ផល្លី** ចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌៖ រយៈពេលជាងពីរឆ្នាំមកហើយ ដែលនាងខ្ញុំ និងគ្រួសារ មកប្រកបមុខរបរទិញលក់អេតចាយ ដោយជួលផ្ទះគេនៅភូមិព្រែកជូនហែម ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល។ នៅថ្ងៃទីមិនចាំ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង ១២ ថ្ងៃត្រង់ នាងខ្ញុំបាន នៅរោងអេតចាយរបស់នាងខ្ញុំ ដល់ម៉ោងប្រហែល ៧ យប់ ថ្ងៃដដែល នាងខ្ញុំជិះម៉ូតូមករោងអេតចាយរបស់កូន



Scanned with CamScanner

ខ្ញុំឈ្មោះ វង នី ភេទស្រី នៅភូមិពុកឫស្សីក្រោម ឃុំពុកឫស្សី ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ដើម្បីចាំរោងអេតចាយឱ្យកូនខ្ញុំ ព្រោះកូនខ្ញុំត្រូវទៅស៊ីការគេនៅស្រុកកំណើត ពេលទៅដល់នាងខ្ញុំឃើញដែករន្ទា ០១ ដើម ដាក់បញ្ឈរនៅមុខរោង ឃើញដូចនេះ នាងខ្ញុំសួរកូនខ្ញុំថា ដែករន្ទានេះឯងទិញពីណាមកថ្លៃប៉ុន្មាន? កូនខ្ញុំឆ្លើយថា ទិញពីមនុស្សប្រុសម្នាក់មិនស្គាល់ឈ្មោះ តម្លៃ ១០.៥០០ (មួយម៉ឺនប្រាំរយ) រៀល ឮដូចនេះនាងខ្ញុំនិយាយស្ដីឱ្យកូនខ្ញុំថា ដែករន្ទានេះនៅថ្មីឯងចេះទិញដែរ ក្រែងទិញចំរបស់ចោរ កូនខ្ញុំឆ្លើយថា អ្នកលក់ដែករន្ទានេះ យាយអះអាងថា ជារបស់គាត់ទើបខ្លួនទិញ។ ដល់ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង ៥ ល្ងាច ពេលនាងខ្ញុំកំពុងនៅរោងទិញអេតចាយកូនខ្ញុំនៅភូមិពុកឫស្សីក្រោម ឃុំពុកឫស្សី ស្រាប់តែកម្លាំងសមត្ថកិច្ចនគរបាល បានមកដល់រោងទិញអេតចាយ រួចសួរខ្ញុំថា អ៊ីទិញដែករន្ទានេះពីណាមក? នាងខ្ញុំឆ្លើយថា ខ្ញុំមិនដឹងទេ តែកូនខ្ញុំទិញដែករន្ទានេះពីមនុស្សមិនស្គាល់ឈ្មោះ តម្លៃ ១០.៥០០ (មួយម៉ឺនប្រាំរយ) រៀល និយាយរួចសមត្ថកិច្ចបានដកហូតដែករន្ទា និងហៅប្ដីនាងខ្ញុំឆ្លើយបំភ្លឺនៅប៉ុស្ដិ៍ ហើយនិយាយប្រាប់ខ្ញុំថា ដែករន្ទានេះត្រូវចោរលួចយកមកលក់នៅរោងអេតចាយនេះ។ លុះដល់ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង ៥ល្ងាច សមត្ថកិច្ចនគរបាលបានហៅនាងខ្ញុំមកបំភ្លឺនៅអធិការដ្ឋាននគរបាលស្រុកខ្សាច់កណ្ដាល។

**សិទ្ធិនិយាយស្ដីរបស់ភាគី បន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល**

**ក. ការកត់សម្គាល់ខ្លីៗរបស់៖**

១. ជនជាប់ចោទឈ្មោះ [redacted] សេងលី៖ សុំឱ្យតុលាការបន្ធូរបន្ថយទោសផង។

**ខ. សេចក្ដីសន្និដ្ឋានថ្លែងសុំរបស់តំណាងអយ្យការ៖**

តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា អង្គហេតុ និងភស្តុតាងស៊ីសង្វាក់គ្នា ជនជាប់ចោទបានឆ្លើយសារភាព និងទទួលកំហុសនៅចំពោះមុខអង្គសវនាការ ដូច្នេះតំណាងអយ្យនៅតែរក្សាការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ២៧៥ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២២ ពីបទ៖ អំពើលួច និងទទួលផលចោរកម្ម តាមមាត្រា ៥៣ និងមាត្រា៥៦ នៃក្រមព្រហ្មទណ្ឌ។

*- ក្រោយពីបាន ស្ដាប់កិច្ចពិភាក្សាដេញដោលរួចហើយ*

*- ក្រោយពីបាន ស្ដាប់សិទ្ធិនិយាយស្ដីរបស់ភាគី បន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល*

**សំអាងហេតុ**

**ក. អំពីសមត្ថកិច្ចនៃការជំនុំជម្រះរឿងក្ដី**

សាលាដំបូងខេត្តកណ្ដាលបានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ **២១៤២ អ.ក** ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ ដែលមានជនជាប់ចោទឈ្មោះ [redacted] **សេងលី** ភេទប្រុស កើតថ្ងៃទី០១ ខែឧសភា ឆ្នាំ១៩៩៨ (អាយុ ២៣ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ឈ្មោះ [redacted] **សួយត្រាយ** ភេទប្រុស កើតឆ្នាំ១៩៩៨ (អាយុ ២៣ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ មកជំនុំជម្រះពីបទ **អំពើលួច** ប្រព្រឹត្តនៅភូមិព្រែកក្របៅទី១ ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីអំឡុងខែធ្នូ និងថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ និងឈ្មោះ [redacted] **រិត** ភេទប្រុស កើតថ្ងៃឆ្នាំ ១៩៩៤ (អាយុ ២៧ ឆ្នាំ) មកជំនុំជម្រះពីបទ **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅភូមិពុកឫស្សីក្រោម ឃុំពុកឫស្សី ស្រុកខ្សាច់



Scanned with CamScanner

កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ៕

**ខ. អំពីដែនកំណត់នៃការប្តឹងចំពោះអង្គហេតុ និងបុគ្គល**

ដែនកំណត់នៃការប្តឹងទៅតុលាការចំពោះអង្គហេតុ តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ តាមមាត្រា ៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងដែនកំណត់នៃការប្តឹងទៅតុលាការចំពោះបុគ្គល តាមមាត្រា ៣៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលនាំឱ្យសាលាដំបូងខេត្តកណ្តាល មានសមត្ថកិច្ចក្នុងការជំនុំជម្រះលើអង្គហេតុដែលប្តឹងមកតុលាការ និងចំពោះជនជាប់ចោទឈ្មោះ[redacted] **សេងលី** ឈ្មោះ [redacted] **សួយត្រាយ** និងឈ្មោះ [redacted] **វិត**៕

**គ. អំពី ពិរុទ្ធភាព**

១. តាមចម្លើយជនជាប់ចោទ ចម្លើយជនរងគ្រោះ ចម្លើយសាក្សី នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ នៅចំពោះមុខតំណាងអយ្យការ និងនៅក្នុងកិច្ចពិភាក្សាដេញដោលបង្ហាញថា អង្គហេតុដែលប្តឹងមកតុលាការ គឺជាអង្គហេតុពិតប្រាកដ ដែលបានកើតឡើង។ តុលាការយល់ឃើញថា ដោយសារអង្គហេតុដែលប្តឹងមកតុលាការនេះ កើតមានឡើង ដែលជាហេតុនាំឱ្យតុលាការទទួលស្គាល់នូវការកកើតនូវអង្គហេតុខាងលើនោះ តុលាការនឹងបន្តពិនិត្យលើបទចោទប្រកាន់ និងអង្គហេតុ តាមរយៈការវាយតម្លៃ និងផ្ទៀងផ្ទាត់ ថាតើអង្គហេតុដែលប្តឹងមកតុលាការនោះ គឺជាបទល្មើសព្រហ្មទណ្ឌដែរឬទេ។

២. តាមសំអាងហេតុចំណុចទី១ នៃចំណុច គ (អំពីពិរុទ្ធភាព) ខាងលើ បង្ហាញថា អំពើរបស់ជនជាប់ចោទ៖

**២.១.** ឈ្មោះ[redacted] **សេងលី** និងឈ្មោះ [redacted] **សួយត្រាយ** បានបំពេញធាតុសត្យានុម័តនៃបទ **អំពើលួច** ប្រព្រឹត្តនៅភូមិព្រែកក្របៅទី១ ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីអំឡុងខែធ្នូ និងថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

**២.២.** ឈ្មោះ [redacted] **វិត** បានបំពេញធាតុសត្យានុម័តនៃបទ **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅភូមិពុកឬស្សីក្រោម ឃុំពុកឬស្សី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ៕

៣. តាមសំអាងហេតុចំណុចទី១ ដល់ទី២ នៃចំណុច គ (ការប្រកាសអំពីពិរុទ្ធភាព) ខាងលើ បានបង្ហាញថា អំពើរបស់ជនជាប់ចោទ៖

**៣.១.** ឈ្មោះ [redacted] **សេងលី** និងឈ្មោះ [redacted] **សួយត្រាយ** បានបំពេញអត្តនោម័តនៃបទ **អំពើលួច** ប្រព្រឹត្តនៅភូមិព្រែកក្របៅទី១ ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីអំឡុងខែធ្នូ និងថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ និងដែលជាចេតនាទុច្ចរិតក្នុងការប្រព្រឹត្តបទល្មើស តាមមាត្រា ៤ នៃក្រមព្រហ្មទណ្ឌ ដោយហេតុថា ជនជាប់ចោទ មានចេតនាទុច្ចរិត ព្រោះជនជាប់ចោទបានដឹងនូវអំពើរបស់ខ្លួនថា ជាបទល្មើស និងអាចព្យាករណ៍បាននូវអំពើរបស់ខ្លួន។



Scanned with CamScanner

៣.២. ឈ្មោះ [redacted] រិត បានបំពេញអត្តនោម័តនៃបទ **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅភូមិពុកឬស្សីក្រោម ឃុំពុកឬស្សី ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ និងដែលជាចេតនាទុច្ចរិតក្នុងការប្រព្រឹត្តបទល្មើស តាមមាត្រា ៤ នៃក្រមព្រហ្មទណ្ឌ ដោយហេតុថា ជនជាប់ចោទ មានចេតនាទុច្ចរិត ព្រោះជនជាប់ចោទបានដឹងនូវអំពើរបស់ខ្លួនថា ជាបទល្មើស និងអាចព្យាករណ៍បាននូវអំពើរបស់ខ្លួន៕

៤. តាមសំអាងហេតុចំណុចទី១ និងទី៣ នៃចំណុច គ (អំពីពិរុទ្ធភាព) ខាងលើបានបង្ហាញថា អំពើរបស់ជនជាប់ចោទ៖

**៤.១.** ឈ្មោះ [redacted] **សេងលី** និងឈ្មោះ [redacted] **សួយត្រាយ** បំពេញធាតុផ្សំនៃបទ **អំពើលួច** ប្រព្រឹត្តនៅភូមិព្រែកក្របៅទី១ ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីអំឡុងខែធ្នូ និងថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

**៤.២.** ឈ្មោះ [redacted] **រិត** បំពេញធាតុផ្សំនៃបទ **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅភូមិពុកឬស្សីក្រោម ឃុំពុកឬស្សី ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ៕

**ឃ. អំពីការទទួល ឬមិនទទួលខុសត្រូវព្រហ្មទណ្ឌ**

តាមរយៈភស្តុតាងក្នុងសំណុំរឿង ពុំមានភស្តុតាងណាមួយអាចបញ្ជាក់បានថា នៅពេលកំពុងប្រព្រឹត្តបទល្មើស ជនជាប់ចោទ កើតមានវិបល្លាសស្មារតី ដែលធ្វើឱ្យបាត់បង់ដឹងខុសត្រូវរបស់ខ្លួន បន្ថយនូវការដឹងខុសត្រូវរបស់ខ្លួន ដោយសារការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារធាតុដែលច្បាប់ហាមឃាត់ តាមមាត្រា ៣១ នៃក្រមព្រហ្មទណ្ឌ។ ហេតុនេះ ជនជាប់ចោទ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើដែលខ្លួនបានប្រព្រឹត្តតាមមាត្រា ២៤ និងមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌ៕

**ង. អំពី ការប្រកាសអំពីពិរុទ្ធភាព**

តាមសំអាងហេតុចំណុច គ (អំពី ពិរុទ្ធភាព) និងចំណុច ឃ (អំពីការទទួលខុសត្រូវព្រហ្មទណ្ឌ) ខាងលើបង្ហាញថា ជនជាប់ចោទឈ្មោះ [redacted] **សេងលី** និងឈ្មោះ [redacted] **សួយត្រាយ** បានបំពេញធាតុសត្យានុម័តនៃបទ **អំពើលួច** ប្រព្រឹត្តនៅភូមិព្រែកក្របៅទី១ ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីអំឡុងខែធ្នូ និងថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ និងឈ្មោះ [redacted] **រិត** បានបំពេញធាតុសត្យានុម័តនៃបទ **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅភូមិពុកឬស្សីក្រោម ឃុំពុកឬស្សី ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ និងមានលក្ខខណ្ឌគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ហេតុដូច្នេះ តុលាការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] **សេងលី** និងឈ្មោះ [redacted] **សួយត្រាយ** មានពិរុទ្ធភាពពីបទ **អំពើលួច** ប្រព្រឹត្តនៅភូមិព្រែកក្របៅទី១ ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីអំឡុងខែធ្នូ និងថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ និងឈ្មោះ [redacted] **រិត** មានពិរុទ្ធភាពពីបទ **ទទួលផលចោរកម្ម**



Scanned with CamScanner

ប្រព្រឹត្តនៅភូមិពុកឬស្សីក្រោម ឃុំពុកឬស្សី ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ៕

**ច. អំពីការពិចារណាលើស្ថានសម្រាល និងស្ថានទម្ងន់ទោស**

អំពើរបស់ជនជាប់ចោទ មិនបានបង្កើតឱ្យមានស្ថានទម្ងន់ទោសណាមួយចំពោះជនជាប់ចោទ តាមមាត្រា ៨៣ ដល់មាត្រា ៩២ នៃក្រមព្រហ្មទណ្ឌ ហេតុដូច្នេះ តុលាការនឹងសម្រេចពុំពិចារណាអំពីស្ថានទម្ងន់ទោសនោះទេ។ ចំពោះ ស្ថានសម្រាលទោស តាមមាត្រា ៩៤ និងមាត្រា ៩៥ នៃក្រមព្រហ្មទណ្ឌ ពុំមានភស្តុតាង ឬសញ្ញាណណាមួយដែលអាចបង្ហាញបានថា កាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈនៃជនជាប់ចោទតម្រូវ ហេតុដូច្នេះ នឹងសម្រេចពុំពិចារណាអំពីស្ថានសម្រាលទោសនោះទេ៕

**ឆ. អំពីរបបនៃការប្រកាសទោស**

**ឆ.១. ការប្រកាសអំពីមូលទោស**

តាមកាលៈទេសៈនៃបទល្មើស តាមបុគ្គលិកលក្ខណៈនៃជនជាប់ចោទ តាមសភាពផ្លូវចិត្ត តាមធនធាននិងបន្ទុក តាមមូលហេតុ ព្រមទាំងកិរិយាមារយាទរបស់ជនជាប់ចោទ ក្រោយពេលប្រព្រឹត្តបទល្មើស តុលាការនឹងសម្រេចប្រកាសមូលទោស ក្នុងទម្រង់ជាការប្រកាសទោសដាក់ពន្ធនាគារតាមមាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌ ដោយសម្រេចប្រកាសទោសដាក់ពន្ធនាគារលើជនជាប់ចោទ៖

១. ឈ្មោះ [redacted] សេងលី ចំនួន ០៦ (ប្រាំមួយ) ខែ ពីបទ **អំពើលួច** ប្រព្រឹត្តនៅភូមិព្រែកក្របៅទី១ ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីអំឡុងខែធ្នូ និងថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

២. ឈ្មោះ [redacted] **ស្វាយត្រាយ** ចំនួន ០៦ (ប្រាំមួយ) ខែ ពីបទ **អំពើលួច** ប្រព្រឹត្តនៅភូមិព្រែកក្របៅទី១ ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីអំឡុងខែធ្នូ និងថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

៣. ឈ្មោះ [redacted] **រិត** ចំនួន ០២ (ពីរ) ឆ្នាំ ពីបទ **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅភូមិពុកឬស្សីក្រោម ឃុំពុកឬស្សី ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

កម្រិតទណ្ឌកម្មនៃទោសដែលត្រូវប្រកាសនេះ ស្ថិតនៅក្នុងកម្រិតអប្បបរមានៃទោសដាក់ពន្ធនាគារចំពោះបទចោទប្រកាន់នីមួយៗ ហើយការសម្រេចទណ្ឌកម្មក្នុងកម្រិតអប្បបរមាបែបនេះ ដោយផ្អែកទៅលើកម្រិតនៃអំពើ កម្រិតនៃព្យសនកម្មដែលបានកើតឡើង ក្នុងកម្រិតតិចតួច។

**ឆ.២. ចំពោះរបបនៃការប្រកាសទោសផ្សេងទៀត**

ចំពោះរបបនៃការប្រកាសទោសផ្សេងទៀត តុលាការនឹងមិនលើកយកមកពិចារណានោះទេ។

**ជ. អំពី វត្ថុចាប់យក**

តាមភស្តុតាងក្នុងសំណុំរឿងបង្ហាញថា វត្ថុចាប់យកដែលរួមមាន ដែករន្ទាសម្រាប់ធ្វើសំណង់ចំនួន ០៣ (បី) ផ្ទាំង ដែលត្រូវបានចាប់យកពីជនជាប់ចោទឈ្មោះ [redacted] សេងលី គឺជាពុំមែនជាឧបករណ៍ សម្ភារៈ ឬវត្ថុណា



Scanned with CamScanner

មួយដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ឬដែលសម្រាប់ប្រព្រឹត្តបទល្មើស, វត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស, ផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស, ឧបភោគភណ្ឌ សម្ភារៈ និងចលនវត្ថុ នៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត ព្រោះវាជាកម្មសិទ្ធនៃទ្រព្យរបស់ជនរងគ្រោះ ហេតុដូច្នេះ តុលាការនឹងសម្រេចធ្វើប្រគល់វត្ថុចាប់យកខាងលើឱ្យម្ចាស់ដើមឈ្មោះ [redacted] ច័ន្ទម៉ូណាក់ វិញ។

**ឈ. អំពី បណ្តឹងរដ្ឋប្បវេណី**

១. ដោយហេតុថា ជនជាប់ចោទឈ្មោះ [redacted] **សេងលី** ឈ្មោះ [redacted] **សួយត្រាយ** ត្រូវបានរកឃើញថា មានពិរុទ្ធភាពលើអង្គហេតុដែលបានប្តឹងមកតុលាការ ហេតុដូច្នេះ តុលាការនឹងសម្រេចពិចារណាអំពីសំណងនៃការខូចខាត និងសំណងជំងឺចិត្ត ប្រសិនបើមានការទាមទារ។

២. យល់ឃើញថា ក្នុងសំណុំរឿងព្រហ្មទណ្ឌ ពុំមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ហេតុនេះ តុលាការនឹងមិនសម្រេចអំពីសំណងរដ្ឋប្បវេណីទេ។

## សេចក្តីសម្រេច

**ក. ប្រកាសថា មានពិរុទ្ធភាពលើជនជាប់ចោទ៖**

១. ឈ្មោះ [redacted] **សេងលី** ភេទប្រុស កើតថ្ងៃទី០១ ខែឧសភា ឆ្នាំ១៩៩៨ (អាយុ ២៣ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ពីបទ **អំពើលួច** ប្រព្រឹត្តនៅភូមិព្រែកក្របៅទី១ ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីអំឡុងខែធ្នូ និងថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

២. ឈ្មោះ [redacted] **សួយត្រាយ** ភេទប្រុស កើតឆ្នាំ១៩៩៨ (អាយុ ២៣ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ពីបទ **អំពើលួច** ប្រព្រឹត្តនៅភូមិព្រែកក្របៅទី១ ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីអំឡុងខែធ្នូ និងថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

៣. ឈ្មោះ [redacted] **វិត** ភេទប្រុស កើតថ្ងៃឆ្នាំ ១៩៩៤ (អាយុ ២៧ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ពីបទ **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅភូមិពុកឬស្សីក្រោម ឃុំពុកឬស្សី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

**ខ. ផ្តន្ទាទោសជាទោសដាក់ពន្ធនាគារលើជនជាប់ចោទឈ្មោះ៖**

១. ឈ្មោះ [redacted]**សងលី** ភេទប្រុស កើតថ្ងៃទី០១ ខែឧសភា ឆ្នាំ១៩៩៨ (អាយុ ២៣ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ចំនួន **០៦ (ប្រាំមួយ) ខែ** ពីបទ **អំពើលួច** ប្រព្រឹត្តនៅភូមិព្រែកក្របៅទី១ ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីអំឡុងខែធ្នូ និងថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

២. ឈ្មោះ [redacted] **សួយត្រាយ** ភេទប្រុស កើតឆ្នាំ១៩៩៨ (អាយុ ២៣ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ចំនួន **០៦ (ប្រាំមួយ) ខែ** ពីបទ **អំពើលួច** ប្រព្រឹត្តនៅភូមិព្រែកក្របៅទី១ ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្តាល ខេត្ត



Scanned with CamScanner

កណ្តាល កាលពីអំឡុងខែធ្នូ និងថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាម មាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

៣. ឈ្មោះ [redacted] **រិត** ភេទប្រុស កើតថ្ងៃឆ្នាំ ១៩៩៤ (អាយុ ២៧ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ចំនួន **០២ (ពីរ) ឆ្នាំ** ពីបទ **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅភូមិពុកឬស្សីក្រោម ឃុំពុកឬស្សី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩៩ និង មាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

**គ.** វត្ថុចាប់យកដែលរួមមាន ដែករន្ទាសម្រាប់ធ្វើសំណង់ចំនួន ០៣ (បី) ផ្តាំង ត្រូវប្រគល់ឱ្យទៅម្ចាស់ដើម ឈ្មោះ [redacted] **ច័ន្ទម៉ូណាក់** ដូចមានអត្តសញ្ញាណខាងលើ វិញ។

***សំណុំរឿងព្រហ្មទណ្ឌនេះ ត្រូវបានជំនុំជម្រះជាសាធារណៈ នៅចំពោះមុខជនជាប់ចោទ ៕***

***សាលក្រមព្រហ្មទណ្ឌនេះប្រកាសជាសាធារណៈ នៅថ្ងៃ សុក្រ ១៣ កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ១១ និង ០០ នាទី នៅសាលសវនាការលេខ ១។***

***ភាគីដែលមានបំណងធ្វើបណ្តឹងទាស់ ឬបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមនេះ ត្រូវធ្វើបណ្តឹងទាស់ និង បណ្តឹងឧទ្ធរណ៍នេះ តាមការកំណត់របស់ច្បាប់។***

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រា [redacted]

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ សុក្រ ១៣ កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ខេត្តកណ្តាល ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២

**ក្រឡាបញ្ជីសវនាការ**

[redacted]

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner